# ប៉ុល ពត និង ក្រុមគ្រួសារ POL POT & HIS FAMILY



សាឡុត ស (ប៉ុល ពត) ជាមួយនឹងកូនស្រីឈ្មោះ ស ផត្ថតា ហៅម៉ាលី ឬ ម៉ុល (រូបថតឆ្នាំ ១៩៨៦)
SALOTH SAR (aka) POL POT & his Daughter SAR PHACHETA aka Maly or Mol (1986)
Photo: Pol Pot Personal Collection

**ប៉ុល ពត** កើតនៅខែមករា ឆ្នាំ១៩២៥ ត្រូវនឹងឆ្នាំឆ្លូវ នៅខេត្តកំពង់ធំ និងជាកូនរបស់ម្ចាស់ដីម្នាក់។ នៅពេលដែលគាត់មានអាយុ៦ឆ្នាំ ប៉ុល ពត បានទៅរស់នៅជាមួយបងប្រុសធ្វើការនៅក្នុងព្រះបរមរាជវាំង។ នៅទីក្រុងភ្នំពេញ ប៉ុល ពត បានសិក្សារៀនសូត្រនៅតាមសាលាបារាំងជាច្រើន ហើយបានបួសជាលោកនេន។

នៅឆ្នាំ១៩៤៩ ប៉ុល ពត បានទទួលអាហារូបករណ៍ទៅសិក្សានៅប្រទេសបារាំង ប៉ុន្តែមិនបានទទួលសញ្ញាប័ត្រទេ។ ក្នុងអំឡុងពេលរៀនសូត្រនៅទីក្រុងប៉ារីស ប៉ុល ពត បានចូលជាសមាជិកបក្សកុម្មុយនីស្តបារាំង ហើយបានចំណាយពេលយ៉ាងច្រើនទៅលើសកម្មភាពនយោបាយ។

នៅឆ្នាំ១៩៥៣ ប៉ុល ពត បានត្រឡប់មកប្រទេសកម្ពុជាវិញ និងបានធ្វើជាគ្រូបង្រៀនប្រវត្តិវិទ្យា និងភូមិវិទ្យានៅសាលាឯកជន ហើយបានចូលរួមជាមួយចលនាកុម្មុយនីស្តខុសច្បាប់មួយ។ ប៉ុល ពត បានរៀបការជាមួយ ខៀវ ប៉ុណ្ណារី នៅឆ្នាំ១៩៥៦។ នៅឆ្នាំ១៩៦០ ប៉ុល ពត មានឋានៈទីបីនៅក្នុងបក្សពលករកម្ពុជាហើយត្រូវបានតែងតាំងជាអនុលេខាបក្សទីពីរក្នុងឆ្នាំ១៩៦១។ ពីរឆ្នាំក្រោយមក គឺនៅក្នុងឆ្នាំ១៩៦៣ ប៉ុល ពត ត្រូវបានតែងតាំងជាលេខាបក្សកុម្មុយនីស្តកម្ពុជា។ ប៉ុល ពត បានដឹកនាំកងទ័ពខ្មែរក្រហមធ្វើសង្គ្រាមប្រឆាំងជាមួយ លន់ នល់។

នៅឆ្នាំ១៩៧៦ ប៉ុល ពត គឺជានាយករដ្ឋមន្ត្រីរបស់កម្ពុជាប្រជាធិបតេយ្យ ហើយបានលាលែងពីតំណែងនៅឆ្នាំ១៩៧៩។ ទោះបីជាយ៉ាងណាក៏ដោយ ប៉ុល ពត នៅជាតែមេដឹកនាំដ៏មានឥទ្ធិពលរបស់ខ្មែរក្រហមដដែល។ ប៉ុល ពត បាននិរទេសខ្លួន ហើយភាគច្រើនរស់នៅក្នុងទឹកដីថៃរហូតដល់ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨ និងបានស្លាប់ដោយជំងឺបេះដូង នៅស្រុកអន្លង់វែងខេត្តឧត្តរមានជ័យ។ សពរបស់ ប៉ុល ពត ត្រូវបានបូជានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៨។



ប្រពន្ធទី២ របស់ ប៉ុល ពត ឈ្មោះ មាន សុភី ហៅ មាន ជាមួយនឹងកូនស្រីឈ្មោះ ស ផត្ថតា
ម្តាយនឹងកូនស្រីសព្វថ្ងៃរស់នៅស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ
Pol Pot's Second Wife MEAN SOPHY & SAR PHACHETA — They are currently living in Malai District, Banteay Meanchey Province
Photo: Pol Pot Personal Collection

**Pol Pot** was born in January 1925 (year of the Ox) in Kampong Thom Province. His father was a prosperous landowner. At the age of six, he went to live with his brother, an official at the Royal Palace. In Phnom Penh, he was educated at a series of French language schools and as a Buddhist novice.

In 1949, he was awarded a scholarship to study in Paris, but failed to obtain a degree. While in Paris, Pol Pot became a member of the French Communist Party and devoted his time to political activity.

Upon returning to Cambodia in 1953, he taught history and geography at a private high school and joined the clandestine communist movement. He married Khieu Ponnary in 1956. In 1960, he ranked number three in the then-Workers' Party of Kampuchea. He was named its second deputy secretary in 1961 and party secretary in 1963. He later led the Khmer Rouge army in its war against the Lon Nol regime.

Pol Pot became prime minister of Democratic Kampuchea in 1976 and resigned in 1979, but remained an active leader of the Khmer Rouge. He lived in exile, mainly in Thailand, until his death in Anlong Veng District, Oddar Meanchey Province, on April 15, 1998. His body was cremated on April 17, 1998.



សាឡុត សេង, បងប្រុស (ស្លាប់)
**SALOTH SENG**, Elder brother (deceased)



សាឡុត រឿង, បងស្រី (ស្លាប់)
**SALOTH ROEUNG,** Oldest sister (deceased)



សាឡុត ញឹប, ប្អូនប្រុស (ស្លាប់)
**SALOTH NHEP,** Younger brother (deceased)

PHOTOS: YOUK CHHANG

**ANLONG VENG PEACE CENTER**
**EXHIBITION 2019:** Youk Chhang
**RESEARCH:** Long Dany, Pheng Pong-Rasy, Som Bunthorn
with Comrade Kong (DK Foreign Affairs: 1975-6 January 1979)
**FOR MORE INFORMATION:** Dr. Ly Sok-Kheang, Director
t: +855 12 570 465 - truthlysokkheang@dccam.org

USAID FROM THE AMERICAN PEOPLE · Sverige · Ziviler Friedensdienst Civil Peace Service · german cooperation · giz · Canada · DC-CAM The Documentation Center of Cambodia